ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍

កិច្ចប្រជុំរួមប្រចាំខែមីនារបស់អគ្គលេខាធិការដ្ឋាន

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧

នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង០៩:០០នាទីព្រឹក នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំប្រចាំខែមីនា ឆ្នាំ២០១៧ ដែលដឹកនាំប្រជុំដោយ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមាន៖ អគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និង មន្ត្រី បុគ្គលិកទាំងអស់ចំនួន៦០នាក់(បញ្ជីវត្តមានភ្ជាប់ជាមួយ)។

អវត្តមាន៖

១-លោកវេជ្ជ.	ស៊ឹម ស៊ូយ៉េង	(បេសកកម្ម)
៣-លោកវេជ្ជ.	ជ ភ័នី	(ច្បាប់)
៤-លោក	ឡាច ឈុនលី	(ច្បាប់)
៥-លោកស្រី	សោម ប៉ូលីន	(ច្បាប់)

គោលបំណងនៃកិច្ចប្រជុំនេះមាន ៖

១-សេចក្តីរាយការណ៍របស់នាយកដ្ឋានបច្ចេកទេស

២-ការងាររដ្ឋបាល

៣-សេចក្តីផ្សេងៗ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបពីគោលបំណងនៃកិច្ចប្រជុំ ដោយផ្តោតទៅលើការងាររដ្ឋបាល និងផ្តល់ឱកាសដល់មន្ត្រី បុគ្គលិកលើកឡើង និងពិភាក្សាដោះស្រាយបញ្ហាដែលកើតមានក្នុងរយៈពេលមួយខែកន្លងទៅនេះ។

១-សេចក្តីរាយការណ៍របស់នាយកដ្ឋានបច្ចេកទេស

- **នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**
  - រៀបចំសេចក្តីព្រាងក្នុងការបង្កើតក្រុមការងារសម្របសម្រួលសង្គមស៊ីវិល និងសហគមន៍នៃគម្រោងមូលនិធិសកល។
  - បន្តការងារ ID poor
  - ទាក់ទងជាមួយក្រសួងព័ត៌មាន ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។
- **នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ**
  - បានចូលរួមជាមួយក្រសួងផែនការ ដើម្បីធ្វើបច្ចុប្បន្នភាពមេរោគអេដស៍ និងជំងឺអេដស៍។
  - បន្តការងារផែនការ៣ឆ្នាំរំកិល ដើម្បីបញ្ជូនទៅក្រសួងផែនការ

- បានចូលរួមកិច្ចប្រជុំធ្វើផែនការថវិកាជាតិឆ្នាំ២០១៨
- បន្តធ្វើការងារ NASA

➢ **នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ**

- បន្តការងារ MCPI ដែលជាគម្រោងមូលនិធិសកល នៅតាមបណ្តាខេត្ត
- បានចូលរួមកិច្ចប្រជុំធ្វើផែនការថវិកាជាតិឆ្នាំ២០១៨
- ចុះបេសកកម្មទៅខេត្តកំពត ដើម្បីពិនិត្យមើលពីការរៀបចំធ្វើផែនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ។

២-ការងាររដ្ឋបាល និងបុគ្គលិក

ឯកឧត្តម **ស៊ិន ពិសិដ្ឋ** ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានជម្រាបជូនអង្គប្រជុំដូចតទៅ ៖

- នៅក្នុងសប្តាហ៍នេះ សវនកម្មជាតិ នឹងពិនិត្យមើលស្ថានភាពមន្ត្រីរាជការក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- តាមការណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មន្ត្រីនៅក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ត្រូវប្រើប្រាស់ Email ជាផ្លូវការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- អនុក្រឹត្យចំនួន២ និងប្រកាស០១ ដែលមានសារៈសំខាន់ចំពោះមន្ត្រីរាជការ មាន៖
  - ✓ អនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលរបស់រាជរដ្ឋាភិបាលកម្ពុជា។
  - ✓ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំរកា នព្វស័ក ពុទ្ធ សករាជ ២៥៦០។
  - ✓ ប្រកាសលេខ១៦៩ ស.ន.ប ស្តីពីការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងសុខាភិបាល។
- កម្មវិធីសូត្រមន្តទទួលអំណរឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស.២៥៦០ នឹងប្រព្រឹត្តទៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង០២:០០នាទីរសៀលនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-សេចក្តីផ្សេងៗ

- **ឯកឧត្តមឱសថ. ឈឹម ឃិនដារ៉ែត** អគ្គលេខាធិការរង បានលើកឡើងថា ដើម្បីកែសម្រួលការងាររវាងអគ្គលេខាធិការដ្ឋាននិងថ្នាក់ដឹកនាំឱ្យមានភាពរលូន និងភាពប្រសើរអគ្គលេខាធិការដ្ឋាន គួរតែធ្វើលិខិតសុំគោលការណ៍ថ្នាក់ដឹកនាំ។
- **ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង** អគ្គលេខាធិការរង បានលើកឡើងថា មន្ត្រីនៅក្នុងអគ្គលេខាធិការដ្ឋាន គួរតែយល់ និងពិចារណា ហើយអនុវត្តការងារទៅតាមហានានុក្រម។

អគ្គលេខាធិការដ្ឋានមានប្រព័ន្ធការងារច្បាស់លាស់ ដូចនេះ គួរតែមិនចាំបាច់ធ្វើលិខិតសុំគោលការណ៍ពីថ្នាក់ដឹកនាំឡើយ ត្រូវអនុវត្តទៅតាមប្រព័ន្ធការងារដែលមានស្រាប់។

- **ឯកឧត្តមវេជ្ជ. ស៊ឹម គឹមសាន** អគ្គលេខាធិការរង បានលើកឡើងថា អគ្គលេខាធិការដ្ឋានមានប្រព័ន្ធការងារហើយ ហេតុនេះ ប្រធាននាយកដ្ឋាននីមួយៗ ត្រូវតែបញ្ជាក់បន្តិចទៅឯកឧត្តមអគ្គលេខាធិការ ដើម្បីសុំការអនុវត្តការងារ វាជាការស្រេចទៅហើយ។

ឯកឧត្តមប្រធានអង្គប្រជុំបានណែនាំដូចខាងក្រោម ៖

១.មន្ត្រីបច្ចេកទេស គួរតែពិចារណា និងចេះបទបែនក្នុងការអនុវត្តការងារ

២.ស្នើមន្ត្រីបច្ចេកទេស នៅគ្រប់សំណើដែលថ្នាក់ដឹកនាំបានបញ្ជាឱ្យអនុវត្តការងារអ្វីមួយ គួរតែជម្រាប និងសុំយោបល់ពីអគ្គលេខាធិការ។

៣.ដើម្បីសម្រួលការងាររវាងអគ្គលេខាធិការដ្ឋាន និងថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋានមិនគួរធ្វើលិខិតសុំគោលការណ៍ពីថ្នាក់ដឹកនាំឡើយ ព្រោះអគ្គលេខាធិការដ្ឋាន មានប្រព័ន្ធការងារហើយ។

៤.ស្នើមន្ត្រី ពិសេសប្រធាននាយកដ្ឋាននីមួយៗ ងាកមកពង្រឹងការងាររដ្ឋបាល និងពង្រឹងវិន័យមន្ត្រីក្រោមឱវាទ។

៥.ស្នើមន្ត្រីបំពេញការងារទៅតាមភារកិច្ច ពិសេសប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ពិនិត្យឡើងវិញនូវបញ្ជីសារពើភ័ណ្ឌ ត្រូវកត់ត្រា តាមដានសម្ភារឱ្យបានច្បាស់លាស់ ហើយត្រូវធ្វើជាប្រចាំឆ្នាំ។

ជាទីបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំបានស្នើឱ្យមន្ត្រីទាំងអស់រក្សាសាមគ្គីភាព កុំបង្កើតបក្សពួក ត្រូវធ្វើការងារជាក្រុម និងចេះទទួលខុសត្រូវការងារ។

អង្គប្រជុំបានបញ្ចប់ នៅវេលាម៉ោង១១និង៣០នាទី នាថ្ងៃខែឆ្នាំដដែលប្រកបដោយភាពរីករាយ៕

អ្នកធ្វើរបាយការណ៍

បានឃើញ និង ឯកភាព	បានពិនិត្យត្រឹមត្រូវ	
ប្រធានអង្គប្រជុំ	**ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**	
		ហ៊ុន ស
វេជ្ជ.តែង គន្ធី	**ស៊ន ពិសិដ្ឋ**	